**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2021, 15:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សេចក្តីសង្ខេប និងសំណើរបស់សហព្រះរាជអាជ្ញា ផ្អែកលើចម្លើយតបរបស់ការិយាល័យរដ្ឋបាល ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលសវនាការលើបណ្តឹងសាទុក្ខដែលគ្រោងនឹងធ្វើនៅថ្ងៃទី១៧ - ២១ ខែឧសភា ឆ្នាំ២០២១**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រ៊ឹម, ប្រធាន
ចៅក្រម Chandra. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**ការិយាល័យរដ្ឋបាល អ.វ.ត.ក**
ឯកឧត្តម តូនី ក្រាញ់ ប្រធានស្តីទី
លោក Knut ROESANDHAUG
អនុប្រធាន

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ការិយាល័យរដ្ឋបាលបានចេញចម្លើយតបរបស់ខ្លួន ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលសវនាការលើបណ្តឹងសាទុក្ខដែលគ្រោងនឹងធ្វើនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ ("ចម្លើយតបរបស់ការិយាល័យរដ្ឋបាល") អមដោយឧបសម្ព័ន្ធ[1]។ ក្នុងថ្ងៃដដែល អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងការពន្យារពេលសវនាការផ្ទាល់មាត់លើបណ្តឹងសាទុក្ខ[2] ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២[3]។

2. សហព្រះរាជអាជ្ញាសូមដាក់ជូនសេចក្តីសង្កេតរបស់ខ្លួន ទាក់ទងនឹងរបៀបធ្វើសវនាការដែលបានគ្រោងទុក និងការកែសម្រួលសាលសវនាការដូចបានរៀបរាប់ក្នុងចម្លើយតប និងឧបសម្ព័ន្ធរបស់ការិយាល័យរដ្ឋបាល។ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះនេះ ធ្វើការកែសម្រួលអ្វីដែលបានលើកឡើងដោយការិយាល័យរដ្ឋបាល ដូចបានគូសបញ្ជាក់ខាងក្រោម។ សំណើនេះធ្វើឡើងដោយសាររបៀបរបប និងការកែសម្រួលខ្លះដែលបានស្នើ មិនស៊ីសង្វាក់ទៅនឹងរបៀបដែលសហព្រះរាជអាជ្ញាបានកំណត់ថាអាចត្រៀមរៀបចំខ្លួន និងបង្ហាញការដេញដោលផ្ទាល់មាត់បានល្អបំផុត និងខ្លះទៀតមិនចាំបាច់ ឬមិនឆ្លុះបញ្ចាំងទៅនឹងការពិតនានាដែលតុលាការនេះកំពុងជួបប្រទះ។

# II. សេចក្តីសង្កេត

## *វិធានការការពារ និងការកែសម្រួលសាលសវនាការ*

3. ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ការិយាល័យរដ្ឋបាលបានស្នើឱ្យមានការកែសម្រួលជារូបវន្តទៅលើសាលសវនាការរបស់ អ.វ.ត.ក និងវិធានការការពារនានា ដើម្បីឱ្យស្របតាមរបាយការណ៍ដែលបានដាក់ភ្ជាប់ជាមួយនឹងចម្លើយតបនេះជា ឧបសម្ព័ន្ធ គ[4]។ សហព្រះរាជអាជ្ញាយល់

[1] ឯកសារ **F61/3** ចម្លើយតបរបស់ការិយាល័យរដ្ឋបាល ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យពន្យារពេលសវនាការបណ្តឹងសាទុក្ខដែលគ្រោងធ្វើនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ("ចម្លើយតបរបស់ការិយាល័យរដ្ឋបាល")។

[2] ឯកសារ **F62** អនុស្សរណៈអន្តរការិយាល័យរបស់ ជ.អ.ត.ក ពី Jonas Nilsson ជាមន្ត្រីច្បាប់ជាន់ខ្ពស់ និងក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។

[3] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[4] ឯកសារ **F61/3.4** ឧបសម្ព័ន្ធ គ ។

ស្រប និងគាំទ្រទាំងស្រុងចំពោះការកែសម្រួល និងវិធានការភាគច្រើនដែលបានស្នើឡើង ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ នៅក្នុងសាលសវនាការ រួមទាំងការតម្លើងដើម្បីពង្រឹងផ្ទាំងកញ្ចក់ និងរបាំងការពារ ការដាក់វិធានការលាងសំអាតដៃក្នុងលក្ខណៈចាប់បង្ខំពេលចូល ការពាក់ម៉ាស់មុខការពារក្នុងលក្ខណៈចាប់បង្ខំ សម្រាប់មនុស្សគ្រប់រូបនៅក្នុងសាលសវនាការពេលមិនត្រូវឡើងថ្លែង និងការអនុវត្តគម្លាតសង្គម[5]។

4. ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាមិនយល់ស្របជាមួយនឹងអនុសាសន៍ផ្សេងៗទៀតដែលមាននៅក្នុងឧបសម្ព័ន្ធ គ នេះទេ មានដូចជា (១) ចំនួនបុគ្គលិកពីការិយាល័យសហព្រះរាជអាជ្ញា("ក.ស.ព") ដែលត្រូវបានអនុញ្ញាតឱ្យចូលរួមសវនាការដោយផ្ទាល់ (តែបួននាក់ គឺសហព្រះរាជអាជ្ញាពីររូបដែលនឹងធ្វើសវនាការដេញដោលផ្ទាល់មាត់ និង "ជំនួយការច្បាប់ពីររូប")[6]; (២) ការបង្កើត "បរិយាកាសអំណោយផល" តាមបានសន្មត តាមរយៈការតម្រូវឱ្យមានបុគ្គលិកតែបួននាក់ដដែល បង្ហាញខ្លួនក្នុងសាលសវនាការសម្រាប់រយៈពេលសវនាការ[7] និង (៣) ការពាក់របាំងមុខការពារសម្រាប់អ្នកធ្វើបទបង្ហាញដែលនឹងឡើងថ្លែងដោយគ្មានកាលកំណត់[8]។

5. ទីមួយ ការកំណត់ចំនួនអ្នកចូលរួមពីការិយាល័យ ក.ស.ព មកត្រឹមចំនួនបួននាក់ដដែល នៅទូទាំងសវនាការ ហើយអនុញ្ញាតឱ្យតែពីរនាក់ក្នុងចំនួនបួននាក់បង្ហាញសារណា មិនអាចធ្វើបានទេសម្រាប់ ក.ស.ព។ អាស្រ័យដោយទំហំ និងភាពស្មុគស្មាញនៃរឿងក្ដី សហព្រះរាជអាជ្ញាបានធ្វើផែនការតាំងពីខែតុលា ឆ្នាំ២០២០ ដែលត្រូវមានអ្នកចូលរួមបង្ហាញចំនួនប្រាំពីរនាក់ អាចដល់ប្រាំបីនាក់ក្នុងនាមអយ្យការ។ សហព្រះរាជអាជ្ញាបានកំណត់ថា វានឹងបានជាជំនួយដ៏ល្អបំផុតដល់អង្គជំនុំជម្រះ ប្រសិនបើសហព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាផ្សេងទៀតនៃការិយាល័យសហព្រះរាជអាជ្ញា ដែលពួកគាត់មានសិទ្ធិធ្វើសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ មានវត្តមានក្នុងសាលសវនាការនៅពេលពួកគាត់ម្នាក់ៗ ធ្វើបទបង្ហាញផ្នែកនៃអំណះអំណាងផ្ទាល់មាត់ដែលពួកគាត់បានទទួលការចាត់តាំង និង

---

[5] ឯកសារ **F61/3.4** ឧបសម្ព័ន្ធ គ EN 01668662-63។

[6] ឯកសារ **F61/3.4** ឧបសម្ព័ន្ធ គ 01668663-64 ("*ភាគី៖ បីភាគីនឹងចូលរួម (សហមេធាវីពីររូបពីភាគីនីមួយៗ) [...]*")។ ជំនួយការច្បាប់៖ អង្គុយកៅអីខាងក្រោយអ្នកតំណាងរបស់ភាគី (កំហិតត្រឹមតែពីររូបសម្រាប់មួយភាគី)"។

[7] ឯកសារ **F61/3.4** ឧបសម្ព័ន្ធ គ EN 01668662 ("ផ្ដល់អនុសាសន៍សម្រាប់បុគ្គលិកដដែលក្នុងរយៈពេល ៥ថ្ងៃ ដើម្បីបង្កើតបរិយាកាសអំណោយផលនៅក្នុងចំណោមបុគ្គលិក ៣០នាក់ ដដែល")។

[8] ឯកសារ **F61/3.4** ឧបសម្ព័ន្ធ គ EN 01668663 ("ប្រសិនបើត្រូវដោះម៉ាស់មុខដើម្បីធ្វើសេចក្ដីថ្លែងក្នុងរយៈពេលយូរ នោះរបាំងការពារមុខនឹងត្រូវបានផ្ដល់អនុសាសន៍ឱ្យប្រើ")។

ឆ្លើយតបទៅនឹងសំណួរផ្សេងៗអំពីបញ្ហាដែលពួកគាត់បានចូលរួមពាក់ព័ន្ធ ក្នុងការត្រៀមរៀបចំយ៉ាងទូលំទូលាយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាតម្រូវឱ្យមានលទ្ធភាពក្នុងការប្តូរវេនអ្នកធ្វើបទបង្ហាញរបស់ ក.ស.ព នៅចម្លោះវគ្គ និងថ្ងៃសវនាការ។

6. ជាការបន្ថែម សហព្រះរាជអាជ្ញាមិនយល់ស្របជាមួយនឹងអនុសាសន៍របស់ការិយាល័យរដ្ឋបាលដែលថា ការកំហិតវត្តមាននៅក្នុងសាលសវនាការចំពោះសមាជិកពី ក.ស.ព តែបួននាក់ដដែល នៅទូទាំងសវនាការ គឺជាការចាំបាច់ដើម្បីបង្កើត "បរិយាកាសអំណោយផល" ដើម្បីជាវិធានការការពារ។ មិនមាន "បរិយាកាសអំណោយផល" សម្រាប់ការពារដូច្នេះនឹងត្រូវបានបង្កើតឡើយ ដោយសារអ្នកដែលនឹងមានវត្តមាននៅក្នុងសាលសវនាការ នឹងមិនត្រូវបានគេបង្ខាំងឱ្យនៅតែមួយកន្លែងជាដាច់ខាតសម្រាប់រយៈពេលពេញមួយសវនាការនោះទេ។ ផ្ទុយទៅវិញ អ្នកចូលរួមរបស់ ក.ស.ព និងធ្វើអន្តរសកម្មភាពជាមួយបុគ្គលិក ក.ស.ព ផ្សេងទៀតនៅក្រៅសាលសវនាការ ហើយនឹងធ្វើដំណើរយ៉ាងហោចណាស់រវាងផ្ទះរបស់ពួកគេ និងតុលាការជារៀងរាល់ថ្ងៃ។ ដូច្នេះ ការផ្លាស់ប្តូរវេនអ្នកចូលរួមរបស់ ក.ស.ព នឹងមិនប៉ះពាល់ទៅលើអត្ថប្រយោជន៍នៃ "បរិយាកាសអំណោយផល" ដូចដែលបានសន្មតនោះទេ។

7. អាស្រ័យហេតុនេះ ដើម្បីជួយសម្រួលដល់ដំណើរការសវនាការឱ្យបានរលូនបំផុតតាមដែលអាចធ្វើបាន សហព្រះរាជអាជ្ញាសូមស្នើឱ្យផ្តល់ការអនុញ្ញាតឱ្យព្រះរាជអាជ្ញាប្រាំមួយរូប មានវត្តមាននៅក្នុងសាលសវនាការនៅក្នុងពេលវេលាជាក់លាក់ណាមួយ ដោយការផ្លាស់ប្តូរវេនគ្នាតាមតម្រូវការចាំបាច់ទៅតាមបញ្ហាដែលបាន និងកំពុងដេញដោល តាមវគ្គសវនាការនីមួយៗ និងថ្ងៃនីមួយៗ។ ការការពារសម្រាប់ព្រះរាជអាជ្ញា ក.ស.ព ប្រាំមួយរូប អាចធានាសុវត្ថិភាពបានតាមរយៈការតម្លើងផ្ទាំងកញ្ចក់ខ្ពស់ដែលមានបីជ្រុង ដោយបំបែកព្រះរាជអាជ្ញាពីររូបក្នុងមួយជួរដែលបានលៃទុកសម្រាប់សហព្រះរាជអាជ្ញា។ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនៃការឆ្លង និងការចម្លងមេរោគកូវីដ-១៩ សហព្រះរាជអាជ្ញាសូមអះអាងថា ព្រះរាជអាជ្ញារបស់ ក.ស.ព ទាំងអស់ ដែលនឹងមានវត្តមាននៅក្នុងសាលសវនាការ យ៉ាងហោចណាស់បានទទួលការចាក់វ៉ាក់សាំងលើកទីមួយ ហើយបើតាមព័ត៌មានដែលបានផ្តល់ដោយការិយាល័យរដ្ឋបាល ពួកគេនឹងទទួលបានការចាក់វ៉ាក់សាំងលើកទីពីរ ប្រហែល ឬនៅចុងខែឧសភានេះ។

8. ទីពីរ អនុសាសន៍ដែលថា អ្នកដែលធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ត្រូវតែពាក់របាំងមុខ សម្រាប់រយៈពេល "វែង" មិនមានការកំណត់នោះ គឺមិនធានាការការពារសុវត្ថិភាពរបស់ពួកគេទេ[9]។ សហព្រះរាជអាជ្ញាលើកឡើងថា វិធានការការពារដែលផ្ដល់ជាអនុសាសន៍អំពី (១) ការរក្សាគម្លាតសង្គម (២) ការពាក់ម៉ាស់ដែលត្រឹមត្រូវតាមវេជ្ជបញ្ជានៅពេលនិយាយ (៣) របាំងកញ្ចក់រវាងអ្នកដែលមានវត្តមាន (៤) ការលាងសម្អាតដៃ និង (៥) ការបាញ់ថ្នាំសម្លាប់មេរោគក្នុងសវនាការក្នុងអំឡុងពេលសម្រាក គឺជាវិធានការការពារសុវត្ថិភាពដែលគ្រប់គ្រាន់ណាស់ទៅហើយ។

9. ខណៈដែលអ្នកដែលកំពុងនិយាយ នឹងត្រូវស្ដាប់ឮដោយអ្នកបកប្រែផ្ទាល់មាត់ ដែលមិននៅកៀកនោះ ការប្រើរបាំងមុខ មានហានិភ័យប៉ះពាល់ដល់លទ្ធភាពរបស់អ្នកបកប្រែ ក្នុងការស្ដាប់ឮអ្នកនិយាយបានច្បាស់ និងត្រឹមត្រូវ។ ការណ៍នេះអាចនាំឱ្យមានការបកប្រែមិនត្រឹមត្រូវ ដែលធ្វើឱ្យខូចខាតដល់គុណភាពនៃការប្រាស្រ័យទំនាក់ទំនងរវាងភាគី និងចៅក្រម។

10. ជាចុងក្រោយ តម្រូវការឱ្យពាក់របាំងមុខនៅពេលនិយាយសម្រាប់រយៈពេលយូរនៅក្នុងសវនាការហាក់ដូចជាមិនត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិនៅតាមតុលាការផ្សេងទៀត ដែលធ្វើសវនាការស្រដៀងគ្នានេះនៅក្នុងប្រទេសនានា ដែលបានប៉ះពាល់ដោយការរីករាលដាលនៃជំងឺនេះក្នុងឆ្នាំ ២០២១ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការយុត្តិធម៌អន្តរជាតិ និងយន្តការសេសសល់អន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់សាលាក្ដីព្រហ្មទណ្ឌ[10]។

### *ការធ្វើការសាកល្បងមុនសវនាការ អ.ជ.ត.ក និងការផ្ដល់ការអនុញ្ញាតចាំបាច់នានា*

---

[9] វិធានការកាត់បន្ថយហានិភ័យជំងឺកូវីដ-១៩ ដែលត្រូវបានអនុវត្តដោយសាលាដំបូងខេត្តព្រះសីហនុ ដូចបានបង្ហាញក្នុងឯកសារ **F61/3.3** ឧបសម្ព័ន្ធ ខ គឺមានលក្ខណៈហួសហេតុ និងមិនមានលក្ខណៈជាការអនុវត្តជាក់ស្ដែងទេ (ពាក់ម៉ាស់ របាំងមុខ ឈុតការពារមេរោគ (hazmat suits) ក្នុងពេលជាមួយគ្នា បន្ថែមលើរបាំងកញ្ចក់)។

[10] *សូមមើល* **ឯកសារភ្ជាប់លេខ ១៖** រូបថត (១) តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") សវនាការលើសាលក្រមក្នុងរឿងក្ដី *Dominic Ongwen* នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ចូលមើលនៅ https://www.youtube.com/watch?v=3WiRobdXzP0 (២) តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") សវនាការខែមីនា និងមេសា ឆ្នាំ២០២១ ចូលមើលនៅ https://www.icj-cij.org/en/multimedia-cases (៣) យន្តការសេសសល់អន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់សាលាក្ដីព្រហ្មទណ្ឌ ("MICT") សវនាការលើអំណះអំណាងបិទកិច្ចពិភាក្សាដេញដោលក្នុងរឿងក្ដី *Stanišić and Simatović* ខែមេសា ឆ្នាំ២០២១ ចូលមើលនៅ https://www.youtube.com/playlist?list=PLXAYOHc1xrLYyE9ciKY-K4dS8BBaHbyjn (៤) MICT, ការជំនុំជម្រះស្ដីពីការមាក់ងាយតុលាការក្នុងរឿងក្ដី *Turinabo និងគូកន* ខែមីនា ឆ្នាំ២០២១ ចូលមើលនៅ https://www.linkedin.com/posts/david-young-7b48091b_irmct-internationallaw-turinabocase-activity-6780498771919937536-dcLJ។

11. ការសាកល្បងឧបករណ៍ និងទម្រង់នានា ដែលបានដំឡើងនៅក្នុង និងក្រៅបន្ទប់សវនាការ គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ភាពជោគជ័យនៃសវនាការនេះ។ សហព្រះរាជអាជ្ញាយល់ឃើញថា ដើម្បីធានាឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់វិធានការកែលម្អចាំបាច់ ការសាកល្បងនេះគួរតែធ្វើឡើងយ៉ាងហោចណាស់រយៈពេល ១៥ថ្ងៃ មុនកាលបរិច្ឆេទសវនាការដែលបានគ្រោងទុក ដោយមានទម្រង់ទាំងអស់រៀបរយជាស្រេចនៅពេលនោះ។ សហព្រះរាជអាជ្ញាក៏លើកឡើងផងដែរថា ល្អបំផុតនោះការសាកល្បងគួរត្រូវធ្វើឡើងដោយមានអ្នកនិយាយទាំងនៅក្នុង និងក្រៅបន្ទប់សវនាការ និងមានអ្នកបកប្រែផ្ទាល់មាត់ ដែលបកបណ្តាក់នូវអ្វីដែលបាននិយាយទៅកាន់អ្នកចូលរួមទាំងអស់។

12. សហព្រះរាជអាជ្ញាក៏សូមលើកឡើងទៀតថា ការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់តម្រូវការវត្តមានផ្ទាល់នៅក្នុងបន្ទប់សវនាការសម្រាប់ការរៀបចំ និងការធ្វើសវនាការ ការធ្វើដំណើរ និងការចូលមកកាន់បន្ទប់សវនាការ គួរទទួលបានឲ្យបានមុនកាលបរិច្ឆេទសវនាការ ដើម្បីធានាថា មានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការកែសម្រួលណាមួយដែលចាំបាច់។

*ផែនការរឿងក្តី និងការរំពឹងរបស់សាធារណជន*

13. ចម្លើយតបរបស់ការិយាល័យរដ្ឋបាលសន្និដ្ឋានថា "សេចក្តីសន្និដ្ឋានផ្ទាល់មាត់អាចត្រូវបានជំនួសដោយកិច្ចដំណើរការជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យស្របទៅនឹងរយៈពេលដែលបានគណនាសម្រាប់សំណុំរឿងនាពេលបច្ចុប្បន្ន និងការរំពឹងទុករបស់សាធារណជន"[11] និងថា ការលើកពេលណាមួយនឹងត្រូវការ "ធនធានហិរញ្ញវត្ថុបន្ថែម"[12]។ ទោះជាយ៉ាងណា ការវាយតម្លៃរបស់សហព្រះរាជអាជ្ញាលើផលប៉ះពាល់នៃការលើកពេល ឬការលុបចោលសវនាការផ្ទាល់មាត់ គឺខុសគ្នា។ តាមទស្សនៈរបស់យើងខ្ញុំ ការលើកពេលសវនាការនឹងមិន៖

(១) នាំឲ្យមានការបង្កើនការចំណាយទេ ដោយសារតែត្រូវការធនធានហិរញ្ញវត្ថុដូចគ្នាសម្រាប់សវនាការ ទោះបីថាតើវាត្រូវធ្វើនៅពេលនេះ ឬពេលក្រោយក្តី។

(២) ផ្លាស់ប្តូរការគ្រោងទុកនៃផែនការបិទបញ្ចប់ទេ ដោយហេតុថា ការងារលើសាលដីកាបណ្តឹងសាទុក្ខនៅ អ.ជ.ត.ក អាចបន្តនៅក្នុងពេលជាមួយគ្នានោះ។

---

[11] ឯកសារ **F61/3** ចម្លើយតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៩។

[12] ឯកសារ **F61/3** ចម្លើយតបរបស់ការិយាល័យរដ្ឋបាល ជើងទំព័រ៣។

(៣) ប៉ះពាល់ដល់ការរំពឹងទុករបស់សាធារណជនអំពី អ.វ.ត.ក យោងទៅលើពេលវេលាដ៏យូរដែលបានកន្លងទៅ ចាប់តាំងពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងការយល់ដឹងរបស់សាធារណជនអំពីបញ្ហាប្រឈមជាក់លាក់ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺនេះ។ និង

(៤) បង្កើតការងារបន្ថែមទៀត ឬពន្យារពេល ជាងការលុបចោលសវនាការចោលទាំងអស់នោះទេ។ ក្រុមមេធាវីការពារក្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ នឹងទំនងជាត្រូវការពេលវេលាច្រើនគួរសម និងធនធានបុគ្គលិកបន្ថែម ដើម្បីរៀបចំការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅកាន់ចម្លើយតបកម្រាស់ ៤៩៥ ទំព័រ របស់សហព្រះរាជអាជ្ញា ដែលក្រោយមកជាលក្ខខណ្ឌរបស់ព្រះរាជអាជ្ញាក្នុងការស្នើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងបណ្តឹងសាទុក្ខរបស់ពួកគេ ទោះបីមានរយៈពេលខ្លីក៏ដោយ។ ការឆ្លើយតបទាំងពីរនេះ ត្រូវការបកប្រែផងដែរ។

## III. **ដំណោះស្រាយដែលស្នើសុំ**

14. ដូច្នេះ អាស្រ័យដូចមូលហេតុដែលបានលើកឡើងខាងលើ សហព្រះរាជអាជ្ញា៖

(១) ស្នើសុំឆ្លាស់គ្នា រវាងវគ្គសវនាការ និងថ្ងៃសវនាការ នៅពេលណាដែលមានការចាំបាច់។

(២) ស្នើសុំឱ្យមានព្រះរាជអាជ្ញាចំនួនប្រាំមួយរូបនៅក្នុងបន្ទប់សវនាការ ក្នុងពេលមួយ ក្នុងពេលសវនាការផ្ទាល់មាត់ ដោយប្រើបីជួរដែលបានកែសម្រួលដូចបានបញ្ជាក់ខាងលើ។

(៣) ស្នើសុំថា អ្នកធ្វើបទបង្ហាញមិនតម្រូវឱ្យពាក់របាំងមុខ។

(៤) ស្នើសុំថា ការសាកល្បងទម្រង់នានា និងឧបករណ៍ទាំងអស់ ដោយមានតំណាងរបស់អ្នកចូលរួមទាំងអស់ និងការអនុញ្ញាតចាំបាច់ ត្រូវធ្វើឡើង យ៉ាងហោចណាស់ ១៥ថ្ងៃ មុនសវនាការដែលបានគ្រោងទុក។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |